គុលាការក្រុងព្រះសីហនុ

<u>សំណុំរឿងព្រហ្មទណ្ឌ</u>

លេខ ៩៧ ចុះថ្ងៃទី ០៣

ខែ មិថុនា ឆ្នាំ ២០០៤

<u>សាលក្រម</u>

លេខ ១០៤ ចុះថ្ងៃទី ០១

ខែ ធ្នូ ឆ្នាំ ២០០៤

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការក្រុងព្រះសីហនុ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញាស្តីទីអមតុលាការក្រុងព្រះសីហនុ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

**<u>មេធាវីការពារ</u>**

លោក [redacted]ធី ( អវត្តមាន )

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៩៧ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៤ ដែលមានជនជាប់ចោទឈ្មោះ :

១-ឈ្មោះ **ន ច** ឈ្មោះហៅក្រៅ **ត** ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ ២ សង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ទីលំនៅសព្វថ្ងៃភូមិ ២ សង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ីនៅផ្ទះ ឪពុកឈ្មោះ **ន ម** (ស) ម្តាយឈ្មោះ **ឡ ឡ** (រ) ប្រពន្ធកូនគ្មាន ទោសពីមុន *គ្មាន* ចាប់ខ្លួនថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៤ ។

២-ឈ្មោះ **ល ខន** ឈ្មោះហៅក្រៅ **ច** ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ ៣ សង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ទីលំនៅសព្វថ្ងៃភូមិ ៣ សង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ីនៅផ្ទះ ឪពុកឈ្មោះ **ល ន** (ស) ម្តាយឈ្មោះ **ឆ** (រ) ប្រពន្ធកូនគ្មាន ទោសពីមុន *គ្មាន* ចាប់ខ្លួនថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៤។

**-ជាប់ចោទពីបទ** "<u>ចោរកម្ម</u>" ប្រព្រឹត្តនៅភូមិ ២ សង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ឈ្មោះ **ហ ច** ភេទស្រី អាយុ ៤៣ឆ្នាំ របររកស៊ីលក់ដូរ មានទីលំនៅសព្វ

សាលក្រមនេះចុះបញ្ជីសាលក្រមរួចហើយ

ក្រុងព្រះសីហនុថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥

ក្រឡាបញ្ជី

[redacted]

ផ្ទៃទីក្រុម ១០ ភូមិ ២ សង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ជាដើមបណ្តឹង ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៤១០ ដសព ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១១៧២ តព ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១២៣៤ តព ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់ប្រធានតុលាការក្រុងព្រះសីហនុ ។

## ឯករឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ វេលាម៉ោង ៩:០០ព្រឹក ឈ្មោះ **ន ង** និងឈ្មោះ **ឈ ទន** បាននាំគ្នាទៅលួចយកឥវ៉ាន់ចាប់ហួយរបស់ឈ្មោះ **ង ង** នៅពេលដែលគាត់ទៅធ្វើបុណ្យឱ្យម្តាយនៅឯស្រុកកំណើត ។ សកម្មភាពរបស់ជនល្មើសទាំងពីរនាក់បានប្រមូលសំភារៈច្រកបាវ រួចហើយបំរុងចេញក៏ត្រូវបានអ្នកជិតខាងឃើញជនល្មើស ក៏រត់គេចខ្លួន ក្រោយមកសមត្ថកិច្ចក៏ចាប់ខ្លួនបានជនល្មើសទាំងពីរនាក់ ។

## នាពេលសវនាការ

-**ន ង** ជាជនជាប់ចោទបានឆ្លើយថា នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ វេលាម៉ោង ០៩ព្រឹក ខ្លួន និង **ឈ ទន** បានបបួលគ្នាទៅលួចយកឥវ៉ាន់នៅផ្ទះរបស់ឈ្មោះ **ង ង** នៅពេលដែលគាត់ និង កូនមិននៅផ្ទះ ។ ពេលចូលទៅដល់ផ្ទះគាត់ឃើញផ្ទះគាត់មានចាក់សោរ ខ្លួនក៏ចូលតាមទ្វារក្រោយចង្ក្រានបាយក៏ឃើញមានកាំបិតប៉ុងតោ ខ្លួនក៏យកទៅគាស់ក្តារឱ្យ **ឈ ទន** នៅឈរមើលជុំវិញ ខ្លាចក្រែងមានម្ចាស់គេមកទាន់ ហើយគាស់ក្តារចំនួន ០២សន្លឹកក៏នាំគ្នាចូលទៅក្នុងផ្ទះធំ ក៏បើកគន្លឹះទ្វារក្នុងផ្ទះនោះ ខ្លួនឃើញមានទូរទស្សន៍. ទូរខោអាវ និង ឃើញសំភារៈចាប់ហួយមានមី. ទឹកដោះគោ. ទឹកក្រូច. ថ្មពិល. ប៊ីចេង ជាដើម ខ្លួន និង **ឈ ទន** គ្មានបំណងយកទូរទស្សន៍ និង របស់របរធំដុំទេ គឺយកតែរបស់របរហូបតែប៉ុណ្ណោះ ក៏យកឥវ៉ាន់មាន មី ១ កេះ. ទឹកដោះគោប្រហែល ២០ កំប៉ុង. ទឹកក្រូច ៧ កំប៉ុង. ថ្មពិលធុនតូចចំនួន ៤២. ប៊ីចេង. ស្កសរ ក្រោយពីប្រមូលបានសំភារៈរួចហើយក៏យកដាក់ក្នុងបាវ រួចសែងចុះមកក្រោមផ្ទះ ស្រាប់តែមានអ្នកជិតខាងស្រែកថា ពីណាគេហ្នឹង ខ្លួន និង **ឈ ទន** មានការភិតភ័យក៏នាំគ្នាទំលាក់បាវដាក់ឥវ៉ាន់ចុះរួចក៏នាំគ្នារត់គេចខ្លួន.ក្រោយមកសមត្ថកិច្ចក៏ចាប់ខ្លួនបាន ។

-ឈ្មោះ **ឈ ទន** ជាជនជាប់ចោទបានឆ្លើយថា ខ្លួនត្រូវឈ្មោះ **ន ង** ជាអ្នកបបួលឱ្យទៅយកឥវ៉ាន់គេដើម្បីយកទៅលក់បានប្រាក់ចែកគ្នាចាយ កន្លងមកខ្លួនត្រូវបានឈ្មោះ **ន ង** ឱ្យទៅលួចយកឥវ៉ាន់គេចំនួនប្រហែល០៥ដងមកហើយបានលុយ គឺឈ្មោះ **ន ង** ជាអ្នកចែកចំណែកឈ្មោះ **ន ង** ខ្លួនមិនដឹងវាលួចឥវ៉ាន់គេប៉ុន្មានដងឡើយរាល់ចម្លើយរបស់ឈ្មោះ **ន ង** គឺខ្លួនឯកភាពទាំងស្រុង គ្រាន់តែបន្ថែមថា ខ្លួនត្រូវបានឈ្មោះ **ន ង** ឱ្យខ្លួនជាអ្នកយាម និង មើលម្ចាស់ផ្ទះ ដល់ពេលគេគាស់ក្តារបាន គេក៏ហៅខ្លួនឱ្យទៅយក និង ជួយប្រមូលឥវ៉ាន់ដាក់ក្នុងបាវរួចសែងចុះមកក្រោមផ្ទះ មានអ្នកជិតខាងគេឃើញគេក៏ស្រែក ហើយក៏នាំគ្នារត់បែកផ្លូវគ្នា បន្ទាប់មកសមត្ថកិច្ចក៏ចាប់ខ្លួនបាន ។

-ឈ្មោះ **ង ង** ជាដើមបណ្តឹងបានឆ្លើយថា ខ្លួនស្គាល់ជនជាប់ចោទទាំងពីរនាក់នេះច្បាស់ណាស់ ព្រោះវាមានទីលំនៅនៅក្បែរខ្លួនដែរ ហើយដឹងថាអ្នកទាំងពីរមានមុខរបរដើរតែលួចឥវ៉ាន់របស់គេនៅក្នុងភូមិប៉ុណ្ណោះ ។ នៅ

ផ្ទះខ្លួនត្រូវបានចោរចូលយកឥវ៉ាន់អស់ចំនួន ២ លើកមកហើយ លើកទី ១ គឺគេលួចយកឥវ៉ាន់អស់គ្មានសល់ សូម្បីតែចានហូបបាយមួយក៏គ្មានសល់ដែរ គឺលួចនៅពេលយប់ ពេលដែលខ្លួនមិននៅផ្ទះ មិនដឹងចោរមួយណាលួចទេ លួចលើកទី ២ នេះ គឺពេលខ្លួនមិននៅផ្ទះដែររវល់ទៅធ្វើបុណ្យសពឱ្យម្តាយ មុនពេលទៅនោះខ្លួនក៏បានផ្ញើផ្ទះ និង អ្នកជិតខាងឱ្យជួយមើល ព្រោះផ្ទះខ្លួនគ្មាននរណានៅចាំទេ ខ្លួនទៅបុណ្យសពនេះមានតែ ០២នាក់ម៉ែកូនប៉ុណ្ណោះ ។ ដល់ពេលត្រឡប់មកវិញអ្នកជិតខាងប្រាប់ ហើយសំភារៈដែលចោរលួចសរុបជាទឹកប្រាក់ចំនួន ០២លានរៀលជាង តែសំភារៈដែលសមត្ថកិច្ចដកហូតបាននោះ គឺមានតិចតួច ចំពោះបញ្ហានេះខ្លួនសុំឱ្យតុលាការផ្តន្ទាទោសតាមច្បាប់ និង ទាមទារសំណងចំនួន ០២លាន ០៥សែនរៀល ។ ខ្លួនសុំបញ្ជាក់ថា ចំពោះលួចលើកទី ២ នេះ គឺអ្នកជិតខាងគេជួយប្តឹង ដើម្បីឱ្យសមត្ថកិច្ចស្វែងរកចាប់ខ្លួនជនល្មើស ។

-ឈ្មោះ **ឃ ខន** ជាប្រធានភូមិ និង ជាសាក្សីបានឆ្លើយថា ជនល្មើសទាំង ០២នាក់នេះកន្លងមកដើរតែលួចឥវ៉ាន់គេក្នុងភូមិ ដូចជាលួចមាន់, កៅអីជ័រ, ខោអាវសំលៀកបំពាក់ជាដើម ពេលលួចបាន គឺយកទៅលក់ ហើយទិញថ្នាំញៀន ( យ៉ាម៉ា ) មកជក់ ឈ្មោះទាំងពីរនាក់ត្រូវបានខាងខ្លួនធ្វើការណែនាំអប់រំជាច្រើនលើកមកហើយ តែឈ្មោះនេះមិនកែប្រែសោះ មុខរបររកស៊ីរបស់អ្នកទាំងពីរ គឺធ្វើចោរលួចប្រហែល ០១ឆ្នាំជាងមកហើយ នៅថ្ងៃកើតហេតុនោះខ្លួនត្រឡប់មកពីប្រជុំវិញ ស្រាប់តែឃើញនៅផ្ទះជនរងគ្រោះគេចោមរោមមើលខ្លួនក៏សួរនាំទៅ ទើបដឹងជនល្មើស ០២នាក់ **ឧ ឃ** និង **ល ខន** ជាអ្នកលួច ឃើញមានសំភារៈមួយបាវចងមាត់ ដែលជនល្មើសយកទៅមិនទាន់ ខ្លួនក៏សហការជាមួយសមត្ថកិច្ចក៏ចាប់ខ្លួនជនល្មើសបានទៅ ។ ឯរឿងរ៉ាវផ្សេងទៀតខ្លួនមិនបានដឹងឡើយ ។

-បានឃើញកំណត់ហេតុទទួលវត្ថុតាងរបស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុ ដែលបានទទួល និង រក្សាទុកវត្ថុតាងចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៤ រួមមានទឹកដោះគោលោសស្វេសញ្ញាខ្លាឃ្មុំចំនួន ១១ កំប៉ុង, ប៊ីចេង ០២ កញ្ចប់, ថ្មពិល ៥៥៥ ចំនួន ៣៦ កូន, មីថៃចំនួន ០១ កេះ, កាំបិតប៉ុងតោចំនួន ០១ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ឧ ឃ** និង **ល ខន** ពីបទចោរកម្ម ប្រព្រឹត្តនៅសង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៤ ជនល្មើសទាំងពីរបានប្រព្រឹត្តបទល្មើសជាច្រើនលើកច្រើនសារ ឃើញថា ឈ្មោះនេះមិនព្រមកែប្រែលត់ដំខ្លួនទេ គឺនៅក្រោយពេលអាជ្ញាធរបានធ្វើការអប់រំណែនាំខ្លួនមក បានន័យថា ឈ្មោះទាំងពីរនៅតែហ៊ានប្រព្រឹត្តបទល្មើសបន្តទៀត ហេតុនេះយើងជាតំណាងអយ្យការសុំឱ្យតុលាការធ្វើការផ្តន្ទាទោសយ៉ាងតឹងរ៉ឹងបំផុត ចំពោះជនល្មើសដោយអនុគ្រោះ ។

-ជនជាប់ចោទទាំងពីរបានឆ្លើយការពារខ្លួន និង ឆ្លើយសំដីចុងក្រោយបង្អស់ថា ការលួចនេះ គឺដោយសារឃ្លានពេក និង ជីវភាពក្រីក្រ ខ្លួនគ្រាន់តែលួចរបស់របរតិចតួចរបស់គេប៉ុណ្ណោះ មិនមែនលួចរបស់របរគេធំដុំទេ ប៉ុន្តែជាច្រើនលើកមែន ហើយខ្លួនទាំងពីរប្តេជ្ញាថា ឈប់ប្រព្រឹត្តអំពើយ៉ាងដូច្នេះទៀត ហេតុដូច្នេះសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្លួនទាំងពីរផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹង

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីឆ្លើយការពារខ្លួនដោយខ្លួនឯង

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

**តុលាការខេត្តព្រះសីហនុ**

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

-តាមការអះអាងរបស់ជនជាប់ចោទទាំងពីរបានឆ្លើយបញ្ជាក់ថា ខ្លួនពិតជាបាននាំគ្នាទៅលួចសំភារៈហូបចុករបស់ដើមបណ្តឹងដែលមានឈ្មោះ ម ម ប្រាកដមែន ។ ប៉ុន្តែការលួចនេះ គឺដោយសារម្ចាស់ផ្ទះមិននៅផ្ទះ លួចតែរបស់របរហូបចុក និង លួចបានឥវ៉ាន់តែយកមិនបានឡើយ ។

-ជនជាប់ចោទទាំងពីរបានបញ្ជាក់ថា ពេលចូលទៅដល់ក្នុងផ្ទះគេឃើញមានទូរទស្សន៍. ទូរ៉ែ គេមិនមានបំណងយក ឬ រើកកាយទេ គ្រាន់តែយកឥវ៉ាន់ចាប់ហ៊ុយប៉ុណ្ណោះ ដូចមានកំណត់ហេតុសមត្ថកិច្ចដកហូតយ៉ាងដូច្នេះការដែលខ្លួនយកឥវ៉ាន់ហូបចុកនេះ គឺដោយសារឃ្លាន និង ជីវភាពក្រីក្រ និង គ្មានមុខរបររកស៊ីធ្វើអ្វី ក៏សំរេចចិត្តធ្វើចោរលួចយ៉ាងដូច្នេះទៅ ។

-ជនជាប់ចោទក៏បានសារភាពខ្លួនឯងថា ខ្លួនធ្លាប់លួចជាច្រើនលើកច្រើនសារមែន ពេលលួចបានយកឥវ៉ាន់ទៅលក់បានប្រាក់យកទៅទិញឥវ៉ាន់ហូបចុកវិញ ហើយក៏ត្រូវសមត្ថកិច្ចមូលដ្ឋានធ្វើការអប់រំណែនាំយ៉ាងដូច្នេះមែន ។

-តាមចម្លើយរបស់ដើមបណ្តឹងថា ក្នុងផ្ទះខ្លួនត្រូវចោរលួចយកឥវ៉ាន់ចំនួន ០២លើកមកហើយ គឺលើកទី ១ យកអស់រលីងគ្មានសល់ នៅពេលដែលខ្លួនមិនបាននៅផ្ទះ ហើយសមត្ថកិច្ចចាប់ជនល្មើសមិនបានលួចលើកទី ២ នេះគឺមិនមានឥវ៉ាន់ដូចជនល្មើសលើកយ៉ាងដូច្នេះទេ គឺបាត់បង់ឥវ៉ាន់ច្រើន សរុបទឹកប្រាក់ប្រហែលជា ០២លានរៀលជាងលើកនេះសមត្ថកិច្ចចាប់ខ្លួនជនល្មើសបាន ។ ដើមបណ្តឹងបានបញ្ជាក់ប្រាប់ក្នុងអង្គសវនាការទៀតថា ជនល្មើសទាំងពីរនេះ នៅក្នុងភូមិនរណាគេក៏ដឹងថា វាជាចោរដែរ គឺដើរលួចតាមផ្ទះជារៀងរាល់យប់ ដូច្នេះការលួចឥវ៉ាន់ទាំងពីរលើកនេះ គ្មាននរណាក្រៅពីជនល្មើសទាំងពីរនាក់នេះដែរ ។

-តាមការអះអាងរបស់សាក្សីជាសមត្ថកិច្ចបញ្ជាក់ថា ជនល្មើសទាំងពីរនាក់នេះត្រូវបានសមត្ថកិច្ចឃាត់ខ្លួនជាច្រើនលើកច្រើនសារ ហើយបានធ្វើការអប់រំណែនាំជាច្រើនដែរមកហើយ ឃើញថា ឈ្មោះនេះនៅតែមិនព្រមកែប្រែអត្តចរិតលួចឥវ៉ាន់ក្នុងភូមិទាល់តែសោះ គឺនៅតែបន្តធ្វើសកម្មភាពដដែល ទោះបីមានទូន្មានព្រានប្រដៅពីអាជ្ញាធរមានសមត្ថកិច្ចយ៉ាងណាក៏ដោយ ។

-បណ្តឹងទាមទារសំណងការខូចខាតមានលក្ខណៈសមស្របតាមច្បាប់ គប្បីតុលាការសំរេចដល់បញ្ហានេះ ។

-ចម្លើយសាក្សី និង ភស្តុតាង មានមូលដ្ឋានគួរឱ្យតុលាការយកជាការបាន ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ន ម ភេទប្រុស អាយុ ១៨ឆ្នាំ និង ឈ្មោះ ល ទន ភេទប្រុស អាយុ ១៨ឆ្នាំ ពីបទចោរកម្ម ប្រព្រឹត្តនៅភូមិ ២ សង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**ហេតុដូច្នេះតុលាការខេត្តព្រះសីហនុ**

**សំរេច :**

**ផ្តន្ទាទោស :**

១-ឈ្មោះ ន ម ហៅ គ ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំ ( បីឆ្នាំ ) គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៤ ។

២-ឈ្មោះ ល ទន ហៅ ចា ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ ( ពីរឆ្នាំ ) គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៤ ។

ពីបទចោរកម្ម ប្រព្រឹត្តនៅភូមិ ២ សង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានឱ្យផ្តន្ទាទោសតាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-ឱ្យឈ្មោះ ន ចា និង ល ទន រួមគ្នាសងថ្លៃសំភារៈគិតជាទឹកប្រាក់ ០២លាន ០៥សែនរៀល ( ២.៥០០.០០០៛០០ ) ទៅដើមបណ្តឹងឈ្មោះ ចា ចា គិតចាប់តាំងពីពេលសាលក្រមនេះចូលជាស្ថាពរ ។

ក្នុងករណីទំល្អិតគ្មានប្រាក់សងធនទណ្ឌទេ ត្រូវដាក់គុកបង្ខំរូបកាយតាមមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៤-វត្ថុតាងរួមមានទឹកដោះគោលេសស្លេសញ្ញារូបខ្លាឃ្មុំចំនួន ១១កំប៉ុង , ប៊ីចេងចំនួន ០២កញ្ចប់ , ថ្មពិល ៥៥៥ ធុនតូចចំនួន ៣៦ កូន, មីវ៉ៃចំនួន ០១ កេះ, កាំបិតប៉ុងតោចំនួន ០១ ត្រូវរឹបអូស និង ប្រគល់ឱ្យ ឈ្មោះ ចា ចា ប្រើប្រាស់ឡើងវិញគិតចាប់ពីថ្ងៃនេះតទៅ ។

សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈនៅចំពោះមុខជនជាប់ចោទ ដើមបណ្តឹង បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំឡុងច្បាប់ ។

**ក្រឡាបញ្ជី** **ចៅក្រមជំនុំជំរះ**

[redacted] [redacted]